# មេរៀនទី ១២០៖ ព្រះយេស៊ូវពន្យល់លោកនីកូដេមពីជីវិតអស់កល្ប

យ៉ូហាន ១៖១-១៧

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/QIQnlzWk-SY

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/-uZLUtJjC3U

**គោលបំណង៖** ព្រះប្រទានជីវិតអស់កល្បដល់យើង។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣៖១៧** *"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ"*

**ចំរៀង** ( *យូធូបលីង* )៖

១. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

២.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc

៣. ចូរសរសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «បោះបាល់»**



សម្ភារៈដែលត្រូវការ៖ បាល់ ២

១. ចែកកុមារជា២ក្រុមស្មើគ្នា

២. ឲ្យកុមារឈរជាជួរ ហើយរើសកុមារម្នាក់ពីក្រុមនីមួយៗ ធ្វើជាអ្នកបោះបាល់

៣. មេក្រុមនឹងធ្វើការបោះបាល់ទៅកាន់កុមារទាំងអស់។ កុមារទីមួយត្រូវចាប់បាល់ ហើយបោះមកឲ្យមេក្រុមវិញ។ បន្ទាប់មកគេត្រូវអង្គុយចុះ។

៤. បន្ទាប់មកមេក្រុមត្រូវឈរនៅកន្លែងដដែល ហើយបោះបាល់ទៅកាន់កុមារទី២ ដែលនៅឈរជាជួរនោះ គេត្រូវចាប់បាល់ហើយបោះត្រឡប់មកឲ្យមេក្រុមវិញរួចអង្គុយចុះ។ បន្តលេងល្បែងនេះរហូតដល់មេក្រុម ពិបាកក្នុងការបោះបាល់នោះ។ សូមបន្តបោះបាល់នោះរហូតដល់កុមារគ្រប់គ្នាអង្គុយចុះ អស់។



៥. ក្រុមណាដែលអាចបោះបាល់បានលឿនជាង នឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កុមារអាចនឹងគិតថា វាមិនងាយស្រួលទេក្នុងការ ទទួលបាននូវជីវិតអស់កល្បនៅឯនគរឋានសួគ៌នោះ ក៏ដូចជាការដែលបោះបាល់ និងចាប់បាល់របស់ កុមារដែលនៅក្រោយគេនោះ។ ប៉ុន្តែយើងនឹងមិនអាចទទួលបាននូវជីវិតអស់កល្បតាមរយៈការធ្វើល្អនេះ ទេ គឺយើងបានទទួលតាមរយៈ សេចក្តីជំនឿជឿលើព្រះយេស៊ូវវិញ។

**៤. ការណែនាំមេរៀន**

តើអ្នកចង់រស់នៅបានប៉ុន្មានឆ្នាំ? ៦០ឆ្នាំ? ៧០ ឆ្នាំ? ១០០ ឆ្នាំ? តើអ្នកចង់នៅរស់ជារៀងរហូតដែរឬទេ? ពីព្រោះព្រះយេស៊ូវបានសុគតលើឈើឆ្កាងជំនួសអំពើបាបរបស់យើង ទើបយើងមានជីវិតអស់កល្បនៅស្ថានសួគ៌បាន! នេះគឺមានន័យថាពួកយើងអាចរស់នៅជារៀងរហូតជាមួយនឹងព្រះជាម្ចាស់នៅឯនគរស្ថានសួគ៌។ ប៉ុន្តែនៅមានបុរសម្នាក់ដែលគាត់នៅតែមិនយល់ពីរឿងនេះ។ តោះ! ទៅមើលទាំងអស់គ្នាថាតើព្រះយេស៊ូវបានពន្យល់បុរសម្នាក់នោះពីជីវិតអស់កល្បយ៉ាងដូចម្តេច!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរនៅថ្ងៃនេះគឺនិយាយអំពីបុរសម្នាក់ដែលមានឈ្មោះថានីកូដេម ដែលគាត់មានចម្ងល់ពីព្រះយេស៊ូវ។ នីកូដេមគឺជាសមាជិកដ៏សំខាន់ម្នាក់នៅក្នុងសង្គមរបស់យូដា។ គាត់គឺជាពួកផារិស៊ី។ នេះគឺមានន័យថា គាត់គឺស្ថិតនៅក្នុងក្រុមមនុស្សមួយក្រុមដែលយកការដើរតាមក្រិត្យវិន័យជារឿងសំខាន់ដើម្បីបង្ហាញថាជនជាតិយូដាគឺជាធ្វើតាមច្បាប់បានល្អ។ ហើយគាត់ក៏ជាពីឡាត់ផងដែរ ដែលមានងារជាអ្នកកាត់ក្តីក្នុងសាសន៍យូដា។ គាត់គឺជាមនុស្សដ៏ឆ្លាតម្នាក់ ដែលបានដឹងច្រើនពីព្រះគម្ពីរ។

ប៉ុន្តែមានរឿងមួយដែលធ្វើឲ្យលោកនីកូដេមមានការភ័ន្តច្រលំ។ គាត់បានឃើញព្រះយេស៊ូវបានធ្វើការអស្ចារ្យជាច្រើន ហើយគាត់ក៏បានឃើញពីការបង្រៀនរបស់ព្រះយេស៊ូវ និងអំណាចរបស់ទ្រង់ផងដែរ។ ហេតុនេះហើយទើបធ្វើឱ្យលោកនីកូដេមបានសម្រេចចិត្តទៅជួបនឹងព្រះយេស៊ូវនៅពេលយប់ និងស្វែងយល់បន្ថែមពីទ្រង់។

គាត់បានមានទូលទៅកាន់ព្រះយេស៊ូវថា “លោកគ្រូ, លោកគ្រូពិតជាអស្ចារ្យណាស់ លោកគ្រូបានធ្វើនូវទីសម្គាល់ជាច្រើន លោកជាគ្រូមកពីព្រះពិត ដ្បិតគ្មានអ្នកណាអាចនឹងធ្វើទីសំគាល់ ដែលលោកធ្វើទាំងនេះបានទេ លើកតែព្រះគង់នៅជាមួយប៉ុណ្ណោះ” ព្រះយេស៊ូវបានមានបន្ទូលតបថា “ប្រាកដមែនបើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ។” ចម្លើយនេះធ្វើឱ្យលោកនីកូដេមឆ្ងល់ជាខ្លាំង គាត់បាននិយាយថា “ធ្វើដូចម្តេចនឹងកើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹងចូលទៅក្នុងពោះម្តាយម្តងទៀត ហើយកើតឡើងវិញបានឬ ។”

ព្រះយេស៊ូវមានបន្ទូលថា “ប្រាកដមែន អ្នកត្រូវតែកើតពីព្រះវិញ្ញាណ។ ឪពុកម្តាយរបស់អ្នកបានផ្តល់ជីវិតនៅលោកិយនេះដល់អ្នក ប៉ុន្តែអ្នកត្រូវតែបានកើតពីព្រះវិញ្ញាណដើម្បីទទួលបាននូវជីវិតខាងឯព្រលឹងវិញ្ញាណ។ ព្រះយេស៊ូវក៏បានប្រាប់លោកនីកូដេមទៀតដែរថា ព្រះទ្រង់ស្រឡាញ់ មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ ព្រះយេស៊ូវក៏បានពន្យល់បន្ថែមទៀតថា ព្រះចាត់ព្រះរាជបុត្រារបស់ទ្រង់ដើម្បីមកសង្គ្រោះមនុស្សលោក អស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ នឹងបានសង្គ្រោះ។ ប៉ុន្តែអស់អ្នកណាដែលមិនព្រមទទួលជឿដល់ទ្រង់នោះនឹងត្រូវវិនាសវិញដោយព្រោះតែ អំពើបាបរបស់ពួកគេ។

មានមនុស្សជាច្រើននៅក្នុងលោកិយនេះដែលដូចជាលោកនីកូដេមដែរ។ ពួកគេមានការយល់ច្រលំអំពីអំណោយនៃសេចក្តីសង្គ្រោះរបស់ព្រះ ហើយនឹងជីវិតអស់កល្បជានិច្ច។ ព្រះទ្រង់ជ្រាបថាមនុស្សយើងត្រូវការការជួយសង្គ្រោះឱ្យរួចពីអំពើបាបរបស់ពួកគេ។ អំពើបាបដ៏ធំបំផុតដែលមនុស្សបានធ្វើនោះគឺ ការដែលពួកគេគិតថាពួកគេអាចរស់បានដោយមិនត្រូវការព្រះនោះទេ។ ប៉ុន្តែ ព្រះទ្រង់ជ្រាបថា មនុស្សមិនអាចជួយសង្គ្រោះខ្លួនឯងបានទេ ពួកគេត្រូវការព្រះសង្គ្រោះ។ ដូច្នេះហើយទើបបានជាព្រះទ្រង់ចាត់ព្រះរាជបុត្រារបស់ទ្រង់ដែលមានព្រះនាមថា ព្រះយេស៊ូវឱ្យមក។ ព្រះយេស៊ូវបានមកក្នុងលោកិយនេះដើម្បី ជួយ

សង្គ្រោះពួកយើងពីទណ្ឌកម្មដែលយើងសមនឹងទទួល ដោយព្រោះអំពើបាបដែលយើងបានប្រព្រឹត្ត។ ព្រះយេស៊ូវគឺជាផ្លូវតែមួយគត់ដែលនាំយើងទៅកាន់ព្រះជាម្ចាស់បាន។ គឺមានតែព្រះគុណតែមួយប៉ុណ្ណោះដែលអាចជួយសង្គ្រោះយើងបាន។ គ្មានអ្វីផ្សេងដែលអាចនាំយើងទៅកាន់ព្រះជាម្ចាស់បានឡើយ។

## ៦. សំនួរពិភាក្សា

១. តើអ្នកណាបានទៅរកព្រះយេស៊ូវនៅពេលយប់នោះ? (*នីកូដេម*)

២. ហេតុអ្វីបានលោកនីកូដេមមានការយល់ច្រលំ? (*ព្រះយេស៊ូវបានប្រាប់គាត់ពីការកើតជាថ្មីខាងព្រលឹងវិញ្ញាណ, ប៉ុន្តែនីកូដេមគិតថាព្រះយេស៊ូវ មានបន្ទូលពីការកើតខាងឯសាច់ឈាម*)

៣. ហេតុអ្វីបានយើងត្រូវការព្រះសង្គ្រោះ? (*យើងមិនអាចជួយសង្គ្រោះខ្លួនឯងពីអំពើបាបបានទេ*)

៤. តើអ្នកណាជាព្រះអង្គសង្គ្រោះ? (*ព្រះយេស៊ូវ, ជាព្រះរាជបុត្រានៃព្រះ*)

៥. តើព្រះយេស៊ូវសង្គ្រោះយើងដោយរបៀបណា?(*ឈ្នួលនៃអំពើបាបគឺជាសេចក្តីស្លាប់ ហើយព្រះយេស៊ូវទ្រង់សុគត់នៅលើឈើឆ្កាងជំនួសអំពើបាបរបស់យើង*)

៦. តើអ្នកណាជាព្រះសង្គ្រោះរបស់អ្នក? (*សូមឱ្យកុមារជាអ្នកឆ្លើយ*)

## ៧. ល្បែងកំសាន្ត «វាយកូនគោល»



សម្ភារៈដែលត្រូវការ៖ ក្រដាស (ធ្វើដំបង និងបាល់)

១. ចែកកុមារជា២ក្រុម ហើយដាក់លេខឲ្យកុមារនីមួយៗ

២. ដាក់ទីនៅចុងសងខាងនៃថ្នាក់រៀន ដោយដាក់ស្បែកជើង




៣. ក្រុមនីមួយៗត្រូវជ្រើសរើសកុមារ ៤នាក់ធ្វើជាអ្នកលេង និងម្នាក់ធ្វើជាអ្នកចាំទី

៤. ឲ្យក្រដាសទៅអ្នកលេងម្នាក់មួយសន្លឹកហើយឲ្យពួកគេរមូលក្រដាសនោះធ្វើជាដំបង។ ហើយប្រើ ក្រដាសឆ្នូលធ្វើជាបាល់ ឬក៏កំប៉ុងសូដាទទេដ៏បាន។

៥. ក្រុមនីមួយៗត្រូវព្យាយាមយកបាល់មកក្នុងវាយបញ្ចូលក្នុង ទីរបស់ក្រុមម្ខាងទៀត ដោយប្រើដំបងរបស់ពួកគេ។ ក្រុមណា ដែលអាចវាយបាល់បញ្ចូលក្នុងទីបានមុននឹងទទួលបាន១ មួយពិន្ទុ។

៦. ប្តូរអ្នកលេងដូច្នេះកុមារអាចលេងបានគ្រប់ៗគ្នា។ ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកយើងមិនចាំបាច់វាយបាល់បញ្ចូលទីដើម្បីបានទទួលជីវិតអស់កល្បនោះទេ។ ព្រះយេស៊ូវគឺបានវាយបាល់បញ្ចូលទីជំនួសពួកយើងរួចហើយ ដូច្នេះ យើងគ្រាន់តែជឿថា ព្រះយេស៊ូវបានទទួលរាល់អំពើបាបរបស់យើង ហើយជួយឲ្យយើងកើតជាថ្មី ដើម្បីឲ្យយើងអាចមានជីវិតអស់កល្បជានិច្ចវិញបាន។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ៣៖១៧** *"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ។"*

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌រូបភាពអំពី **"ព្រះយេស៊ូវ និង លោកនីកូដេម"**

សូមបោះពុម្ពរូបភាពនៅទំព័រខាងក្រោម រួចឱ្យពួកគេផាត់ពណ៌ និងសរសេរនូវខគម្ពីរចងចាំផងដែរ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូះ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវមិនបានយាងមកដើម្បីឱ្យយើងរាល់គ្នាក្លាយជាកាន់សាសនាកាន់ដែលល្អ ដូចជាលោក នីកូដេមនោះទេ។ ប៉ុន្តែព្រះអង្គយាងមកដើម្បីធ្វើឱ្យយើងទាំងអស់គ្នាបានក្លាយជាមនុស្សថ្មីម្នាក់វិញ ជាម្នាក់ដែលអាចមានទំនាក់ទំនងមិត្តភាពនៃជីវិតខាងឯព្រលឹងវិញ្ញាណជាមួយនឹងទ្រង់។ សូមអាន **យ៉ូហាន ៣:១-១៧** សារឡើងវិញ ហើយស្រម៉ៃថាតើព្រះបន្ទូលរបស់ព្រះយេស៊ូវធ្វើឱ្យលោកនីកូដេម មានការយល់ច្រលំបែបយ៉ាងណា។ លោកនីកូដេមគឺជា "អ្នកដែលមានចំណេះដឹងខាងផ្នែកសាសនាម្នាក់" ។
គាត់មានបទពិសោធន៍ខាងឯផ្នែកព្រលឹងវិញ្ញាណក៏មិនតិចដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីចំពោះ ព្រះយេស៊ូវមិនមានអ្វីគួរឱ្យពិសេសនោះទេ។ សូមសួរខ្លួនឯងនៅថ្ងៃនេះថា នៅពេលដែលអ្នកធ្វើការវិនិច្ឆ័យលើផ្នែកព្រលឹងវិញ្ញាណរបស់អ្នក តើអ្នកគិតទៅលើការធ្វើជាអ្នកកាន់សាសនាដ៏ល្អម្នាក់ ឬក៏ការដែលអ្នកស្រឡាញ់ព្រះជាង ?

# ព្រះយេស៊ូវ និង លោកនីកូដេម



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________

______________________________________________________